# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Jun-2012, 09:02
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលសុំការអនុញ្ញាត ក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា

---

**ដាក់ដោយ:**

**សហមេធាវី:**

អាង ឧត្តម
Michael G. KARNAVAS

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន ជាប្រធាន**

ចៅក្រម **យ៉ុ អូត្តារ**

ចៅក្រម **យ៉ា សុខន**

ចៅក្រម **Silvia CARTWRIGHT**

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រមបម្រុង **ធូ មណី**

ចៅក្រមបម្រុង **Claudia FENZ**

**សហព្រះរាជអាជ្ញា:**

ជា លាង
Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**
**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) សុំឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា (“សំណើ”)[1]។ ចម្លើយតបនេះជាការចាំបាច់ ដោយសារថា តាមរយៈសំណើរបស់ខ្លួន សហព្រះរាជអាជ្ញា ស្នើសុំប្រាស្រ័យទាក់ទងដោយមិនសមរម្យ ជាមួយសាក្សីមួយចំនួន/អ្នកដែលអាចក្លាយជាជនសង្ស័យ ដើម្បីផ្តល់ដោយមិនត្រឹមត្រូវ នូវលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ហើយក្នុងការធ្វើបែបនេះ គឺដើម្បីធានាដល់សាក្សី/អ្នកដែលអាចក្លាយជាជនសង្ស័យបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងលើកលែងទោស អនុញ្ញាត និងធានាថា ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ក៏ស្ថាប័ននីតិប្បញ្ញត្តិនៃកម្ពុជា (រដ្ឋសភា និងព្រឹទ្ធសភា) នឹងមិនអនុវត្តអំណាចរបស់ខ្លួន ដែលផ្តល់ដោយរដ្ឋធម្មនុញ្ញក្នុងការធ្វើវិសោធនកម្មច្បាប់ ដូចដែលបានធ្វើរួចមកហើយក្នុងការបង្កើត អ.វ.ត.ក ក្នុងគោលបំណងកាត់ទោសបុគ្គលដែលអាចបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងអំឡុងយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក ទេ។ សំណើនេះគួរត្រូវបដិសេធចោល។ ចម្លើយតបនេះគឺធ្វើឡើងតាមពេលកំណត់ តាមរយៈសារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១២។ អង្គជំនុំជម្រះសាលាដំបូង បានគ្រាន់តែឆ្លើយតបទៅនឹងសំណើ ត្រឹមតែថា “បើផ្អែកតាមតួនាទី និងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក អង្គជំនុំជម្រះយល់ថា វាជាការមួយពុំសមស្របក្នុងការផ្តល់ការធានាអំពីការមិនចោទប្រកាន់ នៅចំពោះមុខតុលាការកម្ពុជាផ្សេងទៀតនោះទេ”[2] មេធាវីការពារក្តីបានសំអាងទៅលើការអះអាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ អង្គជំនុំជម្រះសាលាដំបូង ហើយនិងតាមគោលការណ៍សមភាពនៃមធ្យោបាយការពារក្តី ដែលផ្តល់ថា វាជាសិទ្ធិក្នុងការឆ្លើយតបទៅនឹងសំណើសុំ[3]។ ហេតុដូច្នេះ មេធាវីការពារក្តីនឹងឆ្លើយតបទៅនឹងសំណើនេះទាំងមូលតែម្តង។

---

១ សំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ E200។

២ អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះ និល ណុន ផ្ញើរទៅកាន់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ “អង្គជំនុំជម្រះសាលាដំបូងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា (ឯកសារ E200)” ចុះថ្ងៃទី ១៩ មិថុនា ២០១២ ឯកសារ E200/3។

៣ សារអេឡិចត្រូនិចមកពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើរទៅកាន់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ក្រោមចំណងជើងថា “កម្មវត្ថុ៖ ញត្តិ E200 និងសំណើនានាសុំពេលវេលាបន្ថែមដើម្បីដាក់ការឆ្លើយតប (E200/1 និង E200/2)” ចុះថ្ងៃទី ៦ មិថុនា ២០១២ ដែលថា “យើងទទួលស្គាល់ថាឥឡូវ នៅពេលមានសំណើត្រូវបានដាក់ សិទ្ធិឆ្លើយតបត្រូវបានអនុវត្ត។ អង្គជំនុំជម្រះ គ្រាន់តែមានបំណងដើម្បីខ្លួនមានពេលវេលាដើម្បីច្រើនដើម្បីពិចារណាលើគោលជំហររបស់ខ្លួន។ នៅដំណាក់កាលនេះ យើងទំនងជាផ្តល់អោយមេធាវីការពារក្តី នូវសិទ្ធិដើម្បីឆ្លើយតប ហើយខ្ញុំនឹងទាក់ទងលោក-អ្នកម្តងទៀត។”

*លោកប្រធាន ខ្ញុំចង់និយាយថា ពាក់ព័ន្ធនឹងមន្ទីរ ស២១ សាក្សីរូបនេះបានផ្តល់ភស្តុតាងច្រើនណាស់ ទាក់ទងនឹងការចូលរួមក្នុងសកម្មភាពឧក្រិដ្ឋរបស់គាត់មកទល់នឹងពេលនេះ ហេតុនេះខ្ញុំគិតថា វាសមស្របសម្រាប់ឱ្យគាត់ឆ្លើយតបទៅលើសំណួរ ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងសំណួរនេះ គឺការធ្វើទារុណកម្មនៅមន្ទីរ ម១៣ ដែលមិនអាចមានការចោទប្រកាន់ចំពោះករណីនេះទេ។ សម្រាប់សាក្សីរូបនេះ គាត់នៅតែអាចមានលទ្ធភាពទទួលរងការចោទប្រកាន់ ទោះបីជាលទ្ធភាពនោះមិនទំនងជាអាចមានយ៉ាងណាក៏ដោយ។*

សហព្រះរាជអាជ្ញារងអន្តរជាតិលោក William Smith[4]

*លោកសាក្សីមិនចាំបាច់ឆ្លើយនឹងសំណួរនេះទេ។ ទីមួយ ក្រៅអង្គហេតុ។ ទីពីរ សំណួរដែលមានពិរុទ្ធភាពដាក់បន្ទុកលើកលោក អង្គជំនុំជម្រះបានប្រាប់ហើយ។*

ប្រធានអង្គជំនុំជម្រះលោក **និល ណុន**[5]

១. នៅក្នុងកថាខណ្ឌ ១ សហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាត ដើម្បីផ្តល់នូវលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ("ARNP")[6] ដល់សាក្សីទាំងឡាយដែលនឹងត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ សហព្រះរាជអាជ្ញាមិនអាចផ្តល់នូវលិខិតធានាអះអាងនេះ ដោយមិនរំលោភរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង ច្បាប់ស្តីពីបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") នោះទេ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមិនអាចអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាផ្តល់ការធានាដល់សាក្សី ដែលស្ថិតក្រោមការការពារផ្តាច់មុខរបស់អង្គជំនុំ

---

[4] ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/58.1 ទំព័រ ៧៤ បន្ទាត់៖ ១៩-២៥។ សហព្រះរាជអាជ្ញារងអន្តរជាតិលោក William Smith បានជំទាស់ទៅនឹងសំណួរដែលបានសួរទៅ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច។ *សូមមើលផងដែរ* ទំព័រ ៧២ បន្ទាត់៖ ២៥។

[5] ប្រតិចារឹក ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/59.1 ទំព័រ ១០ បន្ទាត់៖ ៥-៧។ សម្រាប់ការសម្រេចរបស់ប្រធានអង្គជំនុំជម្រះក្នុងនាមអង្គជំនុំជម្រះសាលាដំបូងដែលថា កាំង ហ្គេកអ៊ាវ *ហៅ* ឌុច អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងនៅពេលឆ្លើយសំណួរ ទោះបីការពិតដែលថា ឌុច ត្រូវបានផ្តន្ទាទោស និងមិនអាចទទួលបានដំណោះស្រាយណាមួយតាមផ្លូវច្បាប់នៅ អ.វ.ត.ក ក៏ដោយ *សូមមើល* ទំព័រ ៩ បន្ទាត់ ៤ - ទំព័រ ១២ បន្ទាត់ ៦។

[6] សំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា៖ ឧបសម្ព័ន្ធ ក ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ E200.1។

ជម្រះសាលាដំបូង[7] ដោយមិនរំលោភរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង ច្បាប់ស្តីពីបង្កើត អ.វ.ត.ក វិធាន និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះឡើយ។ សំណើសុំការអនុញ្ញាតនេះត្រូវតែបដិសេធចោល។

២. នៅក្នុងកថាខណ្ឌ ២ សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយបញ្ហាការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង នៅក្នុងសេចក្តីណែនាំមួយចំនួន នាពេលថ្មីៗនេះ[8]។ សំណើនេះមិនចាំបាច់ឲ្យមានទេ។ អង្គជំនុំជម្រះសាលាដំបូងបានបំពេញការងារ អនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ[9] មាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង

[7] មាត្រា៩ នៃក្រមសីលធម៌ចៅក្រមកម្ពុជា (២០០៥) ចែងថា៖ “ចៅក្រមមិនត្រូវធ្វើការស៊ើបអង្កេត ឬ ស៊ើបសួរអង្គហេតុនៃរឿងក្តីដោយឯកឯង និងផ្ទាល់ខ្លួនទាំងក្នុងតុលាការ ទាំងក្រៅតុលាការ លើកលែងតែច្បាប់អនុញ្ញាត”។ “នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា គេចាត់ទុកចៅក្រមអយ្យការជាផ្នែកមួយនៃតុលាការ។ មាត្រា១ នៃក្រមសីលធម៌ចៅក្រមកម្ពុជា (២០០៥) ចែងថា៖ “នៅក្នុងក្រមសីលធម៌នេះ ចៅក្រមមានន័យថា ចៅក្រមអាសនៈ និងចៅក្រមអយ្យការ”។ នៅពេលដែលមេធាវីការពារក្តីបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងទាក់ទងជាមួយសាក្សី អង្គជំនុំជម្រះបានបដិសេធសំណើនោះ។ អនុស្សរណៈរបស់ចៅក្រម និល ណុន ផ្ញើជូនភាគីទាំងឡាយនៅក្នុងសំណុំរឿង០០២៖ “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី” ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E87/3, ទំព័រ២ ដែលក្នុងអនុស្សរណៈនោះអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា៖ “អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលបានស្នើសុំសិទ្ធិក្នុងការទាក់ទងសាក្សី ដេលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីរបស់ភាគីដទៃ ឬបុគ្គលផ្សេងទៀតដែលខ្លួនចាត់ទុកថាអាចធ្វើជាសាក្សីថ្មី” អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងឡាយទាក់ទងជាមួយសាក្សីក្នុងគោលបំណងមួយដែលមានកំណត់។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាជួបទាក់ទងជាមួយអ្នកជំនាញ TCE-38 និង TCE-44 “ក្នុងគោលបំណងនៃការបញ្ជាក់អំពីភាពអាចចូលរួមសវនាការរបស់ពួកគេ និងដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការរៀបចំផែនការការងារ និងការកំណត់កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មរបស់អ្នកជំនាញទាំងពីររូប [និង] … ត្រូវចម្លងជូនផ្នែកអង្គភាពគាំពារសាក្សី និងអ្នកជំនាញនូវសារអេឡិចត្រូនិកស្តីពីការប្រាស្រ័យទាក់ទងការងារទាំងអស់ជាមួយអ្នកជំនាញដែលមានរហស្សនាម TCE-38 និង TCE-44”។ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង៖ “ការស្តាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-38 និង TCE-44,” ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E166។

[8] អនុស្សរណៈពីចៅក្រមប្រធាន និល ណុន ផ្ញើជូនភាគីទាំងឡាយក្នុងសំណុំរឿង០០២ “សេចក្តីណែនាំ ដោយអនុលោមតាមវិធាន ២៨ (សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង)” ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ E193។

[9] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញចែងថា៖ “ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់”។

សិទ្ធិនយោបាយ (“ICCPR”)[10] (ដែលត្រូវតែគោរពនៅ អ.វ.ត.ក អនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ)[11] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង[12] មាត្រា ៣៣ថ្មី និង ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[13] និងវិធាន ២៨[14]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា “គោលបំណងនៃលិខិតធានានេះគឺដើម្បី ... ផ្តល់លទ្ធភាពដល់សាក្សីក្នុងការនិយាយដោយចំហរ និងដោយស្មោះត្រង់”។ អំណះអំណាងនេះក៏ខកខានផងដែរមិនបាននិយាយពីយន្តការមានស្រាប់ ដែលអង្គជំនុំជម្រះសាលាដំបូងយកមកប្រើប្រាស់ ដើម្បីជំរុញឲ្យសាក្សីនិយាយដោយចំហរ និងដោយស្មោះត្រង់

---

១០ មាត្រា១៤ (៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា៖ “ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖ មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ”។

១១ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញចែងថា៖ “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”។

១២ មាត្រា១៣(១) នៃកិច្ចព្រមព្រៀងចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖ “សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី”។

១៣ មាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖ “អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ”។ មាត្រា៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖ “នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ... មិនត្រូវបានគេបង្ខំឱ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឱ្យឆ្លើយសារភាពថាមានកំហុស”។

១៤ វិធាន ២៨(១) ចែងថា៖ “សាក្សីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬ ធ្វើអំណះអំណាងណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សីនេះ ត្រូវយកមកអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី ដូចជាការអង្កេតបឋមដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ការស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និង ដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ”។ *សូមមើលផងដែរ* វិធាន២៨(៣) ដែលចែងផងដែរថា៖ “នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះតម្រូវឲ្យសាក្សីឆ្លើយសំណួរមួយ ឬ ច្រើន សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចធានាចំពោះសាក្សីនោះជាមុន ប្រសិនបើអាចធ្វើបានថាភស្តុ-តាង ដែលជាចម្លើយតបនឹងសំណួរ ៖ **ក**-ត្រូវរក្សាជាការសម្ងាត់ និង មិនត្រូវបើកចំហរដល់សាធារណៈជន និង/ឬ **ខ**-មិនត្រូវបានប្រើប្រាស់ដោយផ្ទាល់ ឬ ដោយប្រយោលប្រឆាំងនឹងសាក្សីនោះ នៅក្នុងការចោទប្រកាន់ បន្តបន្ទាប់ទៀតដែលធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញឡើយ”។

នោះទេ។

*ដំបូង* សាក្សីបានត្រូវបង្ខំឲ្យធ្វើសម្បថ ទៅតាមបរិបទសាសនា និងវប្បធម៌ថា ខ្លួននឹងនិយាយតែការពិត។ សាក្សីត្រូវធ្វើសម្បថថា៖

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ពេទព្រក្ស អារក្សអ្នកតា និងបារមីសក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំឲ្យវិនាសលោញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោង យ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឲ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ[15]។

*ទីពីរ* វិធាន ៣៦(២) អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការជាធរមាន តាមវិធាន ៣៥(២)[16] នៅពេលមាន "មូលដ្ឋានច្បាស់លាស់ជឿថា សាក្សីណាមួយផ្តល់សក្ខីភាពក្លែងក្លាយ ដោយការដឹងជាមុន និងដោយចេតនា"។

*ទីបី* សាក្សីអាចត្រូវបានចោទប្រកាន់ពីបទភូតកុហកតុលាការ ដូចមានចែងក្នុងមាត្រា ៥៤៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ដែលចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "សក្ខីកម្មភូតកុហក ដែលធ្វើក្រោយពីបានស្បថនៅមុខតុលាការ ឬនៅមុខមន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើសកម្មភាពនៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឲ្យសួរចម្លើយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.000.000 (បួនលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល"

---

[១៥] CPC, ឧបសម្ព័ន្ធ។

[១៦] វិធាន៣៥(២) ចែងថា៖ "នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់ បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច ៖ ក-ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។ ខ-ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឲ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី។ ឬ គ-បញ្ជូនបញ្ហានេះទៅឲ្យអាជ្ញាធរមានសមត្ថកិច្ច របស់ព្រះរាជាណាចក្រកម្ពុជា ឬ អង្គការសហប្រជាជាតិ"។

៣. នៅក្នុងកថាខណ្ឌ ៣ សហព្រះរាជអាជ្ញាអះអាងថា លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ជូនដំណឹងទៅសាក្សីថា ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នានាដែលបានកើតឡើងចន្លោះឆ្នាំ ១៩៧៥-៧៩ ពួកគេនឹងមិនត្រូវបានកាត់ទោសនៅ អ.វ.ត.ក ឬនៅតុលាការកម្ពុជាដទៃទៀតតាមច្បាប់កម្ពុជាបច្ចុប្បន្នទេ។ អំណះអំណាងនេះធ្វើឲ្យយល់ខុសដោយសារថា៖ លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ មិនអាចត្រូវបានបង្កើតឡើងដោយកម្រិតស្មោះត្រង់ណាមួយ និងស្ថាប័នតុលាការណាមួយទេ ប្រសិនបើវាមានគោលបំណងធានាដល់សាក្សីថា “[មិន] មានលទ្ធភាពចោទប្រកាន់ដល់រូបគាត់” ទោះបីជាលទ្ធភាពនោះមិនទំនងជាអាចមានយ៉ាងណាក៏ដោយ។ សហព្រះរាជអាជ្ញាមិនអាចផ្តល់នូវការធានាទាំងនេះ ទោះបីមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងក៏ដោយ។ ទាំងសហព្រះរាជអាជ្ញា ទាំងអង្គជំនុំជម្រះសាលាដំបូងមិនអាចផ្តល់ការធានាបែបនេះតាមផ្លូវច្បាប់បាននោះទេ[17] ហើយស្ថាប័នទាំងនេះក៏មិនអាចជ្រៀតជ្រែកចូលក្នុងបុព្វសិទ្ធិរបស់រដ្ឋធម្មនុញ្ញដែលផ្តល់ឲ្យរដ្ឋសភា[18] និងព្រឹទ្ធសភា[19] ដែរ។ ប្រសិទ្ធភាពរបស់វាគឺថាលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ប្រៀបបានដូចជាការអនុគ្រោះទោស៖ វាជាការធានាប្រឆាំងនឹងការចោទប្រកាន់នាពេលអនាគតចំ ពោះការប្រព្រឹត្តឧក្រិដ្ឋកម្មពីអតីតកាល។ មានតែព្រះមហាក្សត្រ និងរដ្ឋសភាទេទើបទទួលបានការអនុញ្ញាតដោយរដ្ឋធម្មនុញ្ញក្នុងការអនុគ្រោះទោស[20]។ ប្រសិនបើសំណើត្រូវបានទទួលយកមែននោះ សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូងតាមរយៈការអនុញ្ញាតតាមសំណើនោះ នឹងចូលរួមយ៉ាងមានប្រសិទ្ធភាពទៅក្នុងការធ្វើរដ្ឋប្រហារធម្មនុញ្ញ៖ ដោយដណ្តើមយក

---

[១៧] មាត្រា៥១ នៃរដ្ឋធម្មនុញ្ញចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖ “អំណាចបែងចែកដាច់ពីគ្នារវាង អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ”។

[១៨] មាត្រា៩០ នៃរដ្ឋធម្មនុញ្ញចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖ “រដ្ឋសភាជាអង្គការតែមួយគត់ ដែលមានអំណាចនីតិប្បញ្ញត្តិ។ អំណាចនេះ រដ្ឋសភាមិនអាចប្រគល់ឲ្យទៅអង្គការ ឬបុគ្គលណាមួយបានឡើយ”។

[១៩] មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖ “ព្រឹទ្ធសភាពិនិត្យហើយឲ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ”។

[២០] មានត្រា២៧ នៃរដ្ឋធម្មនុញ្ញចែងថា៖ “ព្រះមហាក្សត្រមានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស”។ មាត្រា៩០ នៃរដ្ឋធម្មនុញ្ញចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖ “រដ្ឋសភាត្រូវអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ”។ ចំពោះព័ត៌មានបន្ថែមទាក់ទងនឹងសិទ្ធិទទួលបានការលើកលែងទោស សូមមើល បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6 កថាខណ្ឌ ៦៣-៦៥។

អំណាចពីព្រះមហាក្សត្រ រដ្ឋសភា និងព្រឹទ្ធសភា ដោយខុសច្បាប់។ សហព្រះរាជអាជ្ញាក៏ស្នើផង ដែរសុំឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ចែកជូនលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ដល់សាក្សី។ វាជាការមិនត្រឹមត្រូវ និងផ្ទុយពីទម្លាប់អនុវត្ត និងនីតិវិធីជាធរមាន៖ វាមានន័យស្មើនឹង ការបង្កើតទំនាក់ទំនងរវាងសហព្រះរាជអាជ្ញា និងសាក្សី[21]។ ជាងនេះទៀត ដោយអនុញ្ញាតឲ្យ សហព្រះរាជអាជ្ញាអាចប្រាស្រ័យទាក់ទងជាមួយសាក្សីមុនពេលស្តាប់សក្ខីកម្ម អង្គជំនុំជម្រះសាលា ដំបូងនឹងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដណ្តើមយកអំណាចរបស់ខ្លួនដោយខុសច្បាប់ដែរ។

៤. នៅក្នុងកថាខណ្ឌ ៤ សហព្រះរាជអាជ្ញាអះអាងថា "សាក្សីទាំងឡាយដែលអាចមានលទ្ធភាពផ្តល់ នូវសក្ខីកម្មដែលមានតម្លៃភស្តុតាងខ្លាំងបំផុតបាននោះ គឺមានតែអ្នកដែលទំនងជាធ្លាប់បានចូលរួម នៅក្នុងបទឧក្រិដ្ឋក្នុងកម្រិតណាមួយជាក់ស្តែង ឬក្នុងកម្រិតប្រហាក់ប្រហែល"។ ដោយមិនគិតដល់ ខ្លឹមសារនៃអំណះអំណាងនេះ បញ្ហាមួយដែលមេធាវីការពារក្តីមិនអាចយល់ស្របជាមួយនោះគឺថា វាមិនមែនជាយុត្តិកម្ម ដើម្បីអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាផ្តល់ព័ត៌មានខុសដល់សាក្សី។

៥. នៅក្នុងកថាខណ្ឌ ៥ សហព្រះរាជអាជ្ញាអះអាងថា វិធាន ២៨ គ្រាន់តែដោះស្រាយមួយផ្នែកចំពោះ កង្វល់របស់អ្នកដែលអាចក្លាយជាជនសង្ស័យថា ពួកគេនឹងមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងទេ និងថា វិធាននេះមិនបានលើកទឹកចិត្តសាក្សីឲ្យផ្តល់សក្ខីកម្មឲ្យបានពេញលេញ និងដោយស្មោះត្រង់ នោះទេ[22]។ អំណះអំណាងទាំងនេះគ្មានន័យអ្វីទាំងអស់ ហើយខកខានមិនបាននិយាយដល់ យន្តការដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន បន្ថែមលើវិធាន ២៨ ដែលអង្គជំនុំជម្រះសាលាដំបូង

---

[២១] *សូមមើល យោងខាងលើ* លេខ៥។

[២២] សហព្រះរាជអាជ្ញាបន្តអះអាងដោយលើកឧទាហរណ៍ថា៖ "ឧទាហរណ៍ ដូចជាវិធាន២៨ អាចមិនបានចែងអំពីស្ថានភាពមួយ ដែលក្នុងនោះមានសាក្សីម្នាក់បានឆ្លើយ នឹងសំណួរដោយគ្មានការពិត និង/ឬ ដោយមិនព្រមផ្តល់នូវព័ត៌មានដែលមានភវនីយភាព ក្នុងលក្ខណៈមួយដែលថា មិនឃើញច្បាស់ជាក់ស្តែងភ្លាមៗ ឬមួយក៏គ្រាន់តែធ្វើពុតថា ភ្លេចលែងចាំតែប៉ុណ្ណោះ។ នៅក្នុងកាលៈ ទេសៈដែលអង្គជំនុំជម្រះ ឬ ទាំងភាគីណាមួយក្នុងចំណោមភាគីនានាសុទ្ធតែមិនបានជួបជាមួយសាក្សី មុនពេលសាក្សីផ្តល់សក្ខី កម្មនោះ គឺវាមានការលំបាកជាទីបំផុតក្នុងការកំណត់សម្រេចថា តើសាក្សីណាម្នាក់មិនអាចមានលទ្ធភាពផ្តល់ភស្តុតាងបាន ព្រោះដោយសារតែការភ្លេចភ្លាំងលែងចាំ/ការមិនបានដឹង ឬមួយក៏មានមនសិកាមិនចង់ផ្តល់ភស្តុតាងដោយសារតែភ័យខ្លាចក្រែង មានការចោទប្រកាន់ដែរឬទេ? ការធានាអះអាង អំពីមិនចោទប្រកាន់ មានគោលដៅបំពេញការខ្វះចន្លោះនេះ"។ សំណើ កថាខណ្ឌ៦។

យកមកប្រើប្រាស់ដើម្បីជំរុញឲ្យសាក្សីនិយាយដោយចំហរ និងដោយស្មោះត្រង់នោះ[23]។ វិធាន ២៨(១) អនុញ្ញាតឲ្យសាក្សីអាចបដិសេធមិនឆ្លើយសំណួរ ឬធ្វើអំណះអំណាងណាមួយបាន ក្នុងករណីដែលមានលទ្ធភាពនៃការដាក់បន្ទុកមកលើខ្លួនឯង ទោះបីជាលទ្ធភាពនោះមិនទំនងជាអាចមានយ៉ាងណាក៏ដោយ។ វិធាន ២៨(៣) ផ្តល់អំណាចដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្ខំសាក្សីឲ្យឆ្លើយសំណួរណាមួយ ហើយក្នុងការធ្វើបែបនេះ អង្គជំនុំជម្រះសាលាដំបូងអាចផ្តល់នូវការធានាថា ចម្លើយរបស់សាក្សី "នឹងត្រូវរក្សាជាការសម្ងាត់ និងមិនត្រូវបើកចំហរដល់សាធារណជនទេ និង/ឬ មិនត្រូវបានប្រើប្រាស់ដោយផ្ទាល់ ឬ ដោយប្រយោលប្រឆាំងនឹងសាក្សីនោះ នៅក្នុងការចោទប្រកាន់ បន្តបន្ទាប់ទៀតដែលធ្វើឡើងដោយ អ.វ.ត.ក ឡើយ"។ វាជាគំនិតវវើរវាយដែលគិតថា លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ នឹងក្លាយជាឱសថសម្រាប់ជួយឲ្យទទួលបានការពិតនោះ។

៦. នៅក្នុងកថាខណ្ឌ ៦ សហព្រះរាជអាជ្ញាអះអាងថា លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ "បំពេញបន្ថែមពីលើយន្តការទាំងឡាយដែលមានចែងនៅក្នុងវិធាន ២៨"។ អំណះអំណាងនេះកំពុងនាំឲ្យមានការយល់ខុស។ លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ មិនមែនបំពេញបន្ថែមទេ តែវាធ្វើឲ្យមានមោឃភាពចំពោះការធានាដែលមានចែងក្នុងវិធាន ២៨(៣) ដោយការផ្តល់ព័ត៌មានមិនត្រឹមត្រូវដល់សាក្សីថា ការចោទប្រកាន់នាពេលអនាគត ដោយផ្អែកលើសក្ខីកម្មនេះនឹងមិនអាចកើតឡើងទេ។

៧. នៅក្នុងកថាខណ្ឌ ៧ សហព្រះរាជអាជ្ញាអះអាងថា "វិធានជាធរមាននានានៅកម្រិតអន្តរជាតិ បានចែងអំពីយុត្តិសាស្ត្រសម្រាប់អនុវត្តតាមមួយ ក្នុងការធានាអះអាងអំពីការមិនចោទប្រកាន់ ជូនដល់សាក្សីទាំងឡាយដែលមានការភ័យខ្លាចអំពីការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង"។ អំណះអំណាងនេះគ្មានន័យខ្លឹមសារអ្វីទេ នៅពេលគេពិចារណាអំពីចំណុចខ្វះខាតជាក់ស្តែងរបស់តុលាការអន្តរជាតិនានា ដើម្បីផ្តល់នូវការធានាមិនចោទប្រកាន់ចំពោះសាក្សីនៅក្នុងតុលាការជាតិ។ សហព្រះរាជអាជ្ញាគ្រាន់តែផ្តល់នូវឧទាហរណ៍ពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") ដែលបង្ហាញថាតុលាការ ICC អាចត្រឹមតែផ្តល់នូវការធានាថា ការចោទប្រកាន់ទោសនឹងមិនត្រូវធ្វើឡើងនៅ*តុលាការ ICC*

---

[២៣] សូមមើលជើងទំព័រខាងលើ កថាខណ្ឌ ២។

តែប៉ុណ្ណោះ[24]។ ស្រដៀងគ្នានេះដែរ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”)[25] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (“ICTR”)[26] តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (“SCSL”)[27] និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ (“STL”)[28] អាចគ្រាន់តែផ្តល់ការធានាដែលថា នឹងពុំមានការចោទប្រកាន់នោះគឺ *នៅតុលាការនោះ*

---

២៤ មាត្រា ៩៣(២) នៃលក្ខន្តិកៈតុលាការ ICC ចែងថា “តុលាការនេះត្រូវមានអំណាចផ្តល់ការធានាដល់សាក្សី ឬអ្នកជំនាញដែលមានវត្តមាននៅចំពោះមុខតុលាការថា សាក្សី/អ្នកជំនាញនោះនឹងមិនត្រូវបានចោទប្រកាន់ ឃុំខ្លួន ឬត្រូវបានកំហិតសេរីភាពបុគ្គលណាមួយដោយតុលាការ ពាក់ព័ន្ធនឹងបទល្មើសសកម្ម ឬអកម្ម ដែលបានកើតឡើងដោយសារការចាកចេញរបស់បុគ្គលនោះពីរដ្ឋសាមីឡើយ”។

២៥ វិធាន ៩០(ង) នៃវិធាននីតិវិធី និងភស្តុតាងនៅតុលាការ ICTY (“RPE”) ត្រឹមតែធានាដល់សាក្សីថា ពួកគេនឹងមិនត្រូវបានចោទប្រកាន់នៅតុលាការ ICTY តែប៉ុណ្ណោះ៖ “សក្ខីកម្មដែលកើតឡើងដោយការបង្ខំតាមវិធីបែបនេះនឹងមិនត្រូវយកទៅប្រើប្រាស់ជាភស្តុតាង ក្នុងការចោទប្រកាន់បន្តបន្ទាប់ប្រឆាំងនឹងសាក្សី ចំពោះបទល្មើសណាផ្សេងក្រៅពីការផ្តល់សក្ខីកម្មមិនពិតនោះទេ”។ អនុលោមតាមវិធាន ៣៧(ក) នៃ ICTY RPE៖ “រដ្ឋអាជ្ញាត្រូវបំពេញមុខងាររបស់ខ្លួនដែលមានចែងក្នុងលក្ខន្តិកៈនេះ ...”។ មាត្រា ១ នៃលក្ខន្តិកៈតុលាការ ICTY ត្រឹមតែអនុញ្ញាតឱ្យរដ្ឋអាជ្ញាត្រូវអនុម័តតុលាការ ICTY ប៉ុណ្ណោះគឺថា៖ “*តុលាការអន្តរជាតិ*ត្រូវមានអំណាចចោទប្រកាន់ ... អនុលោមតាមបទប្បញ្ញត្តិនៃលក្ខន្តិកៈនេះ” (គូសបញ្ជាក់បន្ថែម)។

២៦ វិធាន ៩០(ង) នៃ ICTR RPE អនុញ្ញាតឱ្យតុលាការ ICTR ត្រឹមតែធានាដល់សាក្សីថា ពួកគេនឹងមិនត្រូវបានចោទប្រកាន់នៅតុលាការ ICTR តែប៉ុណ្ណោះ៖ “សក្ខីកម្មដែលកើតឡើងដោយការបង្ខំតាមវិធីបែបនេះនឹងមិនត្រូវយកទៅប្រើប្រាស់ជាភស្តុតាងក្នុងការចោទប្រកាន់បន្តបន្ទាប់ប្រឆាំងនឹងសាក្សី ចំពោះបទល្មើសណាផ្សេងក្រៅពីការភូតកុហកនោះទេ”។ អនុលោមតាមវិធាន ៣៧(ក) នៃ ICTR RPE៖ “រដ្ឋអាជ្ញាត្រូវបំពេញមុខងាររបស់ខ្លួនដែលមានចែងក្នុងលក្ខន្តិកៈនេះ ...”។ មាត្រា ១ នៃ លក្ខន្តិកៈតុលាការ ICTR ត្រឹមតែអនុញ្ញាតឱ្យរដ្ឋអាជ្ញាត្រូវអនុម័តតុលាការ ICTR ប៉ុណ្ណោះគឺថា៖ “*តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា*ត្រូវមានអំណាចចោទប្រកាន់ ... អនុលោមតាមបទប្បញ្ញត្តិនៃលក្ខន្តិកៈនេះ” (គូសបញ្ជាក់បន្ថែម)។

២៧ វិធាន ៩០(ង) នៃ SCSL RPE អនុញ្ញាតឱ្យតុលាការ SCSL ត្រឹមតែធានាដល់សាក្សីថា ពួកគេនឹងមិនត្រូវបានចោទប្រកាន់នៅតុលាការ SCSL តែប៉ុណ្ណោះ៖ “សក្ខីកម្មដែលកើតឡើងដោយការបង្ខំតាមវិធីបែបនេះនឹងមិនត្រូវយកទៅប្រើប្រាស់ជាភស្តុតាង ក្នុងការចោទប្រកាន់បន្តបន្ទាប់ប្រឆាំងនឹងសាក្សី ចំពោះបទល្មើសណាផ្សេងក្រៅពីបទល្មើសនៃការផ្តល់សក្ខីកម្មមិនពិតតាមពាក្យសម្បថនោះទេ”។ អនុលោមតាមវិធាន ៣៧(ក) នៃ SCSL RPE៖ “រដ្ឋអាជ្ញាត្រូវបំពេញមុខងាររបស់ខ្លួនដែលមានចែងក្នុងលក្ខន្តិកៈនេះ ...”។ មាត្រា ១ នៃ លក្ខន្តិកៈតុលាការ SCSL ត្រឹមតែអនុញ្ញាតឱ្យរដ្ឋអាជ្ញាត្រូវអនុម័តតុលាការ SCSL ប៉ុណ្ណោះគឺថា៖ “*តុលាការពិសេស*ត្រូវ ... មានអំណាចចោទប្រកាន់” (គូសបញ្ជាក់បន្ថែម)។

២៨ វិធាន ១៥០(ច) នៃ STL RPE អនុញ្ញាតឱ្យតុលាការ STL ត្រឹមតែធានាដល់សាក្សីថា ពួកគេនឹងមិនត្រូវបានចោទប្រកាន់នៅតុលាការ STL ទេ៖ “សក្ខីកម្មដែលកើតឡើងដោយការបង្ខំតាមវិធីបែបនេះនឹងមិនត្រូវយកទៅប្រើប្រាស់ជាភស្តុតាង ក្នុងការចោទប្រកាន់បន្តបន្ទាប់ប្រឆាំងនឹងសាក្សី ចំពោះបទល្មើសណាផ្សេងក្រៅពីបទល្មើសនៃការប្រមាថតុលាការ ឬការផ្តល់សក្ខីកម្មមិនពិតនោះទេ”។ អនុលោមតាមវិធាន ៥៥(ខ) នៃ STL RPE៖ “រដ្ឋអាជ្ញាត្រូវបំពេញមុខងាររបស់ខ្លួនដែលមានចែងក្នុង

[29]។ ការចោទប្រកាន់ដោយតុលាការជាតិគឺអាចធ្វើបានសម្រាប់សាក្សី ដែលមិនត្រូវបានចោទប្រកាន់នៅតុលាការអន្តរជាតិ[30]។ ការធានាដែលថា ការចោទប្រកាន់នឹងមិនត្រូវផ្តួចផ្តើមឡើងនៅតុលាការជាតិនឹងរំលោភដល់អធិបតេយ្យភាពរបស់រដ្ឋ។ ផ្ទុយពីការធានាដែលអាចត្រូវបានផ្តល់ដោយតុលាការអន្តរជាតិ លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ មានបំណងផ្តល់ជូនការធានាមួយ ដែលមិនអាចធានាបានដោយ អ.វ.ត.ក ពោលគឺការធានាថា សាក្សីនឹងមិនត្រូវបានចោទប្រកាន់នៅក្នុងតុលាការកម្ពុជា*ណាមួយ*ទេ។

៨. នៅក្នុងកថាខណ្ឌ ៨ សហព្រះរាជអាជ្ញាអះអាងថា ខ្លួន"មិនមានការជំទាស់ចំពោះសាក្សីដែលកំពុងត្រូវបានធ្វើការពិគ្រោះយោបល់ នៅមុនពេលបានទទួលលិខិតធានាអះអាងអំពីការមិនចោទប្រកាន់នោះឡើយ"។ ការពិគ្រោះយោបល់នឹងមិនអាចជួយអ្វីបានចំពោះការផ្តល់ការធានាក្លែងក្លាយនៅក្នុងលិខិតធានាអះអាងអំពីការមិនចោទប្រកាន់។ ជាងនេះទៀត ចំណុចនេះអាចមានអានុភាពចាប់បង្ខំក្នុងការគាបសង្កត់ដល់សាក្សី ដើម្បីឲ្យស្វែងរកការការពារខ្លួនតាមរដ្ឋធម្មនុញ្ញ។

៩. នៅក្នុងកថាខណ្ឌ ៩ សហព្រះរាជអាជ្ញាអះអាងថា អត្ថិភាពនៃ "យន្តការខាងលើ" និង សិទ្ធិអំណាចរបស់តុលាការក្នុងការបង្ខិតបង្ខំសាក្សីនានាឲ្យឆ្លើយនឹងសំណួរផ្សេងៗ ឆ្លុះបញ្ចាំងឲ្យឃើញពីសេចក្តីត្រូវការចាំបាច់ឲ្យមានដំណោះស្រាយចំពោះការភ័យខ្លាចរបស់សាក្សី ពីការចោទប្រកាន់ទោស។ អំណះអំណាងនេះពុំច្បាស់លាស់ និងនាំឲ្យមានការភ័ន្តច្រឡំផងដែរ។ វាមិនច្បាស់ថា តើ

---

លក្ខន្តិកៈនេះ ..."។ មាត្រា ១ នៃលក្ខន្តិកៈ STL ត្រឹមតែអនុញ្ញាតឲ្យរដ្ឋអាជ្ញាអនុវត្តការចោទប្រកាន់នៅតុលាការ STL តែប៉ុណ្ណោះគឺថា៖ "*តុលាការពិសេស* ត្រូវបានយុត្តាធិការលើបុគ្គល ..." (គូសបញ្ជាក់បន្ថែម)។

[២៩] នៅឯគណៈវិនិច្ឆ័យពិសេស (Special Panels) នៃតុលាការ Dili District Court ពុំមានផ្តល់នូវការធានាបែបនេះទេ។ វិធាន ៣៥.៤ នៃវិធាននីតិវិធីព្រហ្មទណ្ឌអន្តរកាលចែងថា៖ "សាក្សីមិនត្រូវបានបង្ខំឲ្យធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងទេ។ ប្រសិនបើប្រធានអង្គជំនុំជម្រះយល់ថា សំណួរណាមួយដែលសួរទៅសាក្សីអាចនាំឲ្យមានចម្លើយដែលបណ្តាលឲ្យដាក់ពិរុទ្ធលើសាក្សីនោះ ប្រធានអង្គជំនុំជម្រះត្រូវជូនដំណឹងទៅសាក្សីពីសិទ្ធិរបស់ខ្លួនក្នុងការមិនឆ្លើយតបទៅនឹងសំណួរនោះ"។ បទប្បញ្ញត្តិលេខ 2000/30 ស្តីពីវិធាននីតិវិធីព្រហ្មទណ្ឌអន្តរកាល ឯកសារ UNTAET/REG/2000/30 ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០០។

[៣០] ឧទាហរណ៍ សាក្សីម្នាក់នៅតុលាការ ICTY ឈ្មោះ Milos Stupar ក្រោយមកត្រូវបានចោទប្រកាន់នៅក្នុងតុលាការជាតិនៅប្រទេសបូស្នី និងហ៊ឺហ្សេហ្គោវីណា។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់ Blagojević និង Jokić* សំណុំរឿង IT-02-60-T ប្រតិចារឹក ថ្ងៃទី ២៨-២៩ ខែ មេសា ឆ្នាំ ២០០៤; *រឿងក្តី ការិយាល័យរដ្ឋអាជ្ញានៅប្រទេសបូស្នី និងហ៊ឺហ្សេហ្គោវីណា តទល់នឹង Stupar និងអ្នកដទៃទៀត* (សាលក្រមតុលាការសាលាដំបូង) សំណុំរឿងលេខ X-KR-05/24 (បោះពុម្ពផ្សាយនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩)។

សហព្រះរាជអាជ្ញានិយាយពី "យន្តការខាងលើ" ចង់សំដៅដល់អ្វីនោះទេ។ យើងមិនត្រូវនិយាយឲ្យលើស ឬឲ្យខ្វះទេថា យើង*ត្រូវតែ*លាតត្រដាងឲ្យបានពេញលេញដល់សាក្សី ពីផលប៉ះពាល់ដែលអាចកើតមានដោយសារសក្ដីកម្មរបស់ខ្លួន រួមទាំងការចោទប្រកាន់ផងដែរ។

១០. នៅក្នុងកថាខណ្ឌ ១០ សហព្រះរាជអាជ្ញាបានប្រើប្រាស់ពាក្យថា លិខិតធានាអះអាងអំពីការមិនចោទប្រកាន់។ ពាក្យថា លិខិតធានាអះអាងអំពីការមិនចោទប្រកាន់មានភាពផ្ទុយគ្នាដោយផ្ទាល់ទៅនឹងតំណាងព្រះរាជអាជ្ញាដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិលោក William Smith នៅពេលដែលគាត់ធ្វើអន្តរាគមន៍ក្នុងនាម កាំង ហ្កេកអ៊ាវ *ហៅ* ឌុច នៅក្នុងសំណុំរឿង ០០២ និងបានលើកឡើងថា ទោះបីជា ឌុច ត្រូវបានផ្ដន្ទាទោស និងលែងទទួលបានដំណោះស្រាយក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួនក្ដី "ក៏លទ្ធភាពនៃការចោទប្រកាន់ចំពោះរូបគាត់នៅតែមាន ទោះបីជាលទ្ធភាពនោះមិនទំនងជាអាចមានយ៉ាងណាក៏ដោយ"[31]។ ជាការសន្និដ្ឋានមកវិញគឺថា ក្នុងនាមជាមន្ត្រីតុលាការមួយរូប សហព្រះរាជអាជ្ញារងអន្តរជាតិលោក Smith មិនបានធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងយល់ខុស ចំពោះភាពជាតំណាងរបស់គាត់នោះទេ ហើយក៏មិនបាននិយាយចេញមកដោយភាពល្ងង់ខ្លៅនោះដែរ[32]។

១១. នៅក្នុងកថាខណ្ឌ ១១ សហព្រះរាជអាជ្ញាអះអាងថា ផ្នែកទី ១ នៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ គឺជាការធានាចំពោះសាក្សីថា សហព្រះរាជអាជ្ញានឹងមិនផ្ដើមគំនិតចោទប្រកាន់ប្រឆាំងនឹងសាក្សីទាំងនោះ ចំពោះព្រឹត្តិការណ៍នានាដែលបានកើតឡើងចន្លោះឆ្នាំ ១៩៧៥-៧៩ ទេ[33]។

---

៣១ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/58.1 ទំព័រ ៧៤ បន្ទាត់៖ ១៩-២៥។

៣២ ការផ្ដល់ព័ត៌មានខុសដោយដឹងជាមុន និង/ឬ ការលាក់បំបាំងព័ត៌មានពីសាក្សីនោះ សហព្រះរាជអាជ្ញានឹងរំលោភដល់មាត្រា ៦(២) នៃកិច្ចព្រមព្រៀង ("សហព្រះរាជអាជ្ញាត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់") មាត្រា ១៩ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក (សហព្រះរាជអាជ្ញាត្រូវ៖ "មានចរិតលក្ខណៈ និងស្មារតីខ្ពស់") និងមានក្រមសីលធម៌វិជ្ជាជីវៈ៖ (វិធាន ៥ (គ) នៃក្រមសីលធម៌សម្រាប់ស្មារក្ដីនៅអូស្ត្រាលីខាងត្បូង (South Australian Barristers' Conduct Rules) ចែងថា៖ "ស្មារក្ដីជាមេធាវីជំនាញនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ត្រូវបំពេញការងារដោយស្មោះត្រង់ ត្រឹមត្រូវ មានជំនាញពិតប្រាកដ និងមានសមត្ថភាពនិងយកចិត្តទុកដាក់ក្នុងការងារផងដែរ"។ មាត្រា ១ នៃក្រមសីលធម៌ចៅក្រមកម្ពុជា (ឆ្នាំ ២០០៥) កត់សម្គាល់ថា ក្រមសីលធម៌ចៅក្រមក៏អនុវត្តដូចគ្នាចំពោះព្រះរាជអាជ្ញាដែរ។ មាត្រា ១៨ ចែងថា៖ "ចៅក្រមត្រូវតែជាបុគ្គលសុចរិត"។

៣៣ ផ្នែកទី១ នៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ចែងថា៖ "យើងនឹងមិនផ្ដើមការចោទប្រកាន់ណាមួយប្រឆាំងនឹងលោក/លោកស្រីឡើយ ចំពោះព្រឹត្តិការណ៍ណាមួយដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពីថ្ងៃទី ១៧ ខែ

អំណះអំណាងនេះគ្មានន័យខ្លឹមសារទេ និងនាំឲ្យមានការយល់ខុសទៀតផង។ ទោះបីសហព្រះរាជអាជ្ញាមានអំណាចឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ក៏ពិតមែន តែទោះបីមាន ឬមិនមានជំនួយពីសហគមន៍អន្តរជាតិក៏ដោយ ក៏គ្មានអ្វីអាចរារាំងមិនឲ្យរដ្ឋសភា និងព្រឹទ្ធសភា ក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដើម្បីពង្រីកវិសាលភាពយុត្តិការរបស់ អ.វ.ត.ក ទៅលើបុគ្គលជាច្រើនទៀត ឬដកចេញ ឬកំហិតអំណាចឆន្ទានុសិទ្ធិនេះបានដែរ[34]។

១២ នៅក្នុងកថាខណ្ឌ ១២ សហព្រះរាជអាជ្ញាអះអាងថា ផ្នែកទីពីរនៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ បានជម្រាបទៅដល់សាក្សីឲ្យបានជ្រាបថា អនុលោមតាមច្បាប់របស់កម្ពុជាបច្ចុប្បន្ន គឺពួកគេមិនអាចត្រូវបានធ្វើការចោទប្រកាន់ ចំពោះព្រឹត្តការណ៍ណាមួយ ដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានទេ[35]។ ការបញ្ជាក់នេះ គឺពុំមានន័យខ្លឹមសារឡើយ និងនាំឲ្យមានការភ័ន្តច្រឡំ។ ដូចដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់នៅក្នុងកថាខណ្ឌ ១៧ "រដ្ឋសភា កម្ពុជាអាចនឹងអនុម័តច្បាប់ដែលអនុញ្ញាតឲ្យមានការចោទប្រកាន់នៅក្នុងស្រុក"។ លើសពីនេះទៀត ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អាចត្រូវបានធ្វើវិសោធនកម្ម ដូច្នេះហើយច្បាប់សារធាតុដែលត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់នេះ អាចយកមកអនុវត្តបាននៅតុលាការកម្ពុជាផ្សេងៗទៀត។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២០០១ រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលមិនត្រឹមតែអនុញ្ញាតឲ្យ អ.វ.ត.ក កាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិ ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើង មុនការប្រកាសឲ្យប្រើច្បាប់នេះ

---

មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩"។ សំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា៖ ឧបសម្ព័ន្ធ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ E200.1។

[៣៤] យុត្តាធិការនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បច្ចុប្បន្នមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ថា៖ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩"។

[35] ស្រដៀងគ្នានេះដែរ នៅក្នុងកថាខណ្ឌ ១៤ និង ១៥ សហព្រះរាជអាជ្ញាអះអាងថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផ្តល់យុត្តាធិការឲ្យតែនៅក្នុង អ.វ.ត.ក ប៉ុណ្ណោះ មិនមែនផ្តល់យុត្តាធិការទៅឲ្យតុលាការក្នុងស្រុកធម្មតាឡើយ។

ប៉ុណ្ណោះទេ[36] ប៉ុន្តែថែមទាំងបានពន្យារអាជ្ញាយុកាលទៀត ដូច្នេះបទឧក្រិដ្ឋនានាដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នៅតែត្រូវបានយកមកធ្វើការជំនុំជម្រះ[37]។ យោងតាមអង្គបុរេជំនុំជម្រះ កម្ពុជាមានកាតព្វកិច្ចធ្វើការជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានកើតឡើងនៅក្នុងយុត្តាធិការដែនដីរបស់ខ្លួន[38]។ តាមរយៈការអនុញ្ញាតឲ្យមានលិខិតធានាអះអាងអំពីការមិនចោទប្រកាន់នោះ សហព្រះរាជអាជ្ញា រួមទាំងអង្គជំនុំជម្រះសាលាដំបូងផងនោះ នឹងបញ្ជូនសារថាជនរងគ្រោះមិនអាចរំពឹងថាទទួលបានយុត្តិធម៌ នៅក្នុងស្ថាប័នតុលាការណាមួយឡើយក្នុងប្រទេសកម្ពុជា។ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (“CHRAC”) និងអង្គការសហប្រជាជាតិ (“UN”) ថ្មីៗនេះបានគូសបញ្ជាក់អំពីការពុំមានយុត្តិធម៌សម្រាប់ជនរងគ្រោះ។ CHRAC បានអំពាវនាវឲ្យកេរដំណែល អ.វ.ត.ក ដាក់បញ្ចូលនូវការជំនុំជម្រះដោយតុលាការជាតិ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងរបបខ្មែរក្រហម[39]។ អង្គការសហ

---

[36] កាលប្បវត្តិនៃការបង្កើត អ.វ.ត.ក អាចរកមើលបាននៅគេហទំព័រ http://www.eccc.gov.kh/en/chronologies។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១។ មាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា “ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។

[37] ចំពោះសារតារ សូមមើល ញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងមាត្រា ៣ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក (បទល្មើសនៅក្នុងច្បាប់ជាតិ) នៅ អ.វ.ត.ក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D382 កថាខណ្ឌ ១៣-២៤។

[38] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២១៣។

[39] “CHRAC ជឿជាក់ផងដែរថា អ.វ.ត.ក ត្រូវបានចាត់ទុកថាមានតួនាទីមួយទូលំទូលាយ ជាជាងគ្រាន់តែធ្វើការជំនុំជម្រះលើបទ ឧក្រិដ្ឋតិចតួចប៉ុណ្ណោះទេ។ អ.វ.ត.ក គួរតែផ្តួចផ្តើមឲ្យមានការពិភាក្សាឲ្យបានទូលំទូលាយ អំពីសម័យកាលខ្មែរក្រហម និងរបៀបទទួលស្គាល់អតីតកាល។ ឥឡូវនេះដល់ពេលវេលាចាប់ផ្តើមពិចារណាអំពីកេរដំណែលរបស់តុលាការ ការជំនុំជម្រះទោសដោយតុលាការជាតិប្រឆាំងនឹងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងវិធានការផ្សេងៗទៀត ដូចជា គណៈកម្មការស្វែងរកការពិត ដើម្បីដោះស្រាយរឿងអតីតកាល”។ យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ CHRAC បានឲ្យដឹងថា *CHRAC អំពាវនាវឲ្យអង្គការសហប្រជាជាតិតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីមួយរូបដើម្បីបំពេញកន្លែងទំនេររបស់ចៅក្រម Laurent Kasper-Ansermet* ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១២។

ប្រជាជាតិបានសម្តែងក្តីព្រួយបារម្ភថា ជនរងគ្រោះដោយសារអំពើហិង្សាលើផ្លូវភេទ ក្នុងអំឡុងរបបខ្មែរក្រហម មិនអាចស្វែងរកយុត្តិធម៌បានឡើយ។

> ការរួមចំណែករបស់ អ.វ.ត.ក គឺដើម្បីធានាថា បទឧក្រិដ្ឋនៃអំពើហិង្សាលើផ្លូវភេទនៅក្នុងរបបខ្មែរក្រហម ត្រូវបានស៊ើបអង្កេត និងផ្តន្ទាទោសយ៉ាងត្រឹមត្រូវ។ រដ្ឋាភិបាលកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការធានាថា អ្នកនៅរស់រានមានជីវិតត្រូវទទួលបាននូវការគាំទ្រដែលពួកគេត្រូវការ ហើយថា ច្បាប់ត្រូវបានប្រតិបត្តិ និងគោលនយោបាយត្រូវបានអនុវត្តដើម្បីបញ្ឈប់នូវការបន្តកើតមានអំពើហិង្សាលើស្ត្រីនៅក្នុងប្រទេសកម្ពុជា នៅក្រោយពេលជម្លោះ។ មានតែធ្វើដូច្នេះទេ ទើបជនរងគ្រោះនឹងអាចទទួលបាននូវយុត្តិធម៌[40]។

សហព្រះរាជអាជ្ញាបញ្ជាក់នៅក្នុងកថាខណ្ឌ ១២ ទៀតថា ផ្នែកទីពីរនៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ជួយគាំទ្រចំពោះគោលដៅនៃការទទួលបានកិច្ចសហប្រតិបត្តិការពេញលេញពីសាក្សី និងការផ្តល់លទ្ធភាពដល់តុលាការដើម្បីបញ្ជាក់អំពីការពិត។ ការអះអាងនេះគឺជាការស្រមើស្រមៃ។ ការផ្តល់នូវព័ត៌មានមិនត្រឹមត្រូវទៅឲ្យសាក្សី មិនអាចជួយក្នុងការបញ្ជាក់អំពីការពិតបានឡើយ។

១៣ នៅក្នុងកថាខណ្ឌ ១៣ សហព្រះរាជអាជ្ញាអះអាងថា "ឧក្រិដ្ឋកម្មអន្តរជាតិមិនមានកំណត់អាជ្ញាយុកាលឡើយ [ហើយថា] ចារីនៃបទឧក្រិដ្ឋទាំងនេះ អាចត្រូវបាននាំខ្លួនមកចំពោះមុខតុលាការក្នុងស្រុកនៅពេលណាមួយក៏បាន ឲ្យតែច្បាប់ក្នុងប្រទេសនោះបានអនុម័តឡើងដែលអនុញ្ញាតឲ្យមានការចោទប្រកាន់តាមប្រព័ន្ធច្បាប់របស់ប្រទេសនោះ"។ ទោះបីជាការអះអាងនេះមិនស៊ីសង្វាក់គ្នាពេញលេញជាមួយនឹងការបកស្រាយច្បាប់របស់មេធាវីការពារក្តីយ៉ាងណាក៏ដោយ[41] សម្រាប់គោល

[40] Margot Wallstrom អ្នកតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីអំពីអំពើហិង្សាលើផ្លូវភេទក្នុងពេលជម្លោះ *លិខិតផ្ញើជូននិពន្ធនាយក កាសែត ឌឹ ខេបូឌា ដេលី ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ មានចំណងជើងថា ជនរងគ្រោះដោយសារអំពើហិង្សាលើផ្លូវភេទក្នុងរបបខ្មែរក្រហមនៅតែស្វែងរកយុត្តិធម៌។*

[41] សូមមើល ឧទាហរណ៍ អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពើបំពានបំពានធ្ងន់ធ្ងរ) ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E43 (ដែលត្រូវបានសង្ខេបនៅក្នុងសេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានាពេលអនាគត ដែលត្រូវបានចេញជំនួសឲ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E51/4)

បំណងនៃចម្លើយតបនេះ មេធាវីការពារក្តីកត់សម្គាល់ថា ការអះអាងនេះគឺជាការទទួលស្គាល់ដោយសហព្រះរាជអាជ្ញាថា លិខិតធានាអះអាងអំពីការមិនចោទប្រកាន់មិនមែនពិតប្រាកដទាំងស្រុងឡើយ។

១៤ នៅក្នុងកថាខណ្ឌ ១៤ និង ១៥ សហព្រះរាជអាជ្ញាអះអាងថា ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ "គ្មានប្រតិសកម្មនោះទេ" និង "មិនផ្តល់យុត្តាធិការទៅឲ្យតុលាការក្នុងស្រុកធម្មតា ទាក់ទិននឹងឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ទេ"។ ការអះអាងនេះគឺមិនត្រឹមត្រូវឡើយ។ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ អាចត្រូវបានធ្វើវិសោធនកម្មដើម្បីយកមកអនុវត្តជាប្រតិសកម្ម ចំពោះសាក្សីដែលបានទទួលលិខិតធានាអះអាងអំពីការមិនចោទប្រកាន់។ ការធ្វើវិសោធនកម្មបែបនេះទៅលើក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ នឹងអនុលោមទៅតាមមាត្រា ១៥(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[42] – និងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ – ដែលអនុញ្ញាតឲ្យមានការលើកលែងការអនុវត្តច្បាប់ជាប្រតិសកម្ម ចំពោះបទឧក្រិដ្ឋអន្តរជាតិ[43]។ តាមពិត

---

លើកទឡ្ហីករណ៍ថា ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺមានអាជ្ញាយុកាល។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារ D427/1/6 កថាខណ្ឌ ១០៣-៣៥ ដែលលើកទឡ្ហីករណ៍ថា ដោយសារតែបទឧក្រិដ្ឋអន្តរជាតិមិនត្រូវបានចែងនៅក្នុងច្បាប់ជាតិនៅមុនអំពើនានាដែលត្រូវបានចោទប្រកាន់បានកើតឡើងនៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ និងដោយសារតែច្បាប់កម្ពុជាដែលអាចអនុវត្តបាននៅពេលនោះបានចែងអំពីការហាមឃាត់ដ៏តឹងរ៉ឹងប្រឆាំងនឹងការអនុវត្តច្បាប់ជាប្រតិសកម្ម ជាជាងមានចែងនៅក្នុង ICCPR នោះ បទឧក្រិដ្ឋអន្តរជាតិមិនអាចត្រូវបានផ្តន្ទាទោសនៅ អ.វ.ត.ក ដែលជាតុលាការជាតិនៃប្រទេសកម្ពុជាឡើយ។

[42] មាត្រា ១៥ នៃ ICCPR ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា "១. គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្ត ... ២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើ ឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ"។

[43] កត់សម្គាល់ថា គោលជំហររបស់មេធាវីការពារគឺថា មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (ច្បាប់ដែលអាចអនុវត្តបានក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩) មានលក្ខណៈតឹងរ៉ឹងជាងមាត្រា ១៥(២) នៃ ICCPR និងតម្រូវឲ្យបទឧក្រិដ្ឋទាំងនោះត្រូវបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិ មុនពេលដែលបទឧក្រិដ្ឋទាំងនោះអាចត្រូវបានផ្តន្ទាទោសនៅក្នុងតុលាការជាតិនៃប្រទេសកម្ពុជា។ ក.ស.ព ធ្លាប់បានអះអាងជំទាស់ប្រឆាំងទៅនឹងគោលជំហរនេះ ដោយបានអះអាងថា "មិនមានតម្រូវការក្នុងការបង្ហាញថាបទល្មើសព្រហ្មទណ្ឌនោះត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ជាតិ ដែលអាចអនុវត្តបាននៅពេលអំពើនោះត្រូវបានប្រព្រឹត្តនោះទេ"។ ចម្លើយតបរួម របស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ

សហព្រះរាជអាជ្ញា ធ្លាប់បានទទួលស្គាល់ថា "មាត្រា ១៥(១) នៃ ICCPR មិនរារាំងដល់ការចោទប្រកាន់លើបុគ្គលណាមួយ ដោយអនុលោមតាមច្បាប់ដែលចូលជាធរមានក្រោយពីមានព្រឹត្តិការណ៍ដែលជាកម្មវត្ថុនៃការចោទប្រកាន់នោះទេ ប្រសិនបើនៅពេលមានព្រឹត្តិការណ៍នោះ អំពើសកម្ម (ឬអំពើអកម្ម) ដែលនាំឲ្យមានការចោទប្រកាន់មានលក្ខណៈឧក្រិដ្ឋ មិនថាក្រោមច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិនោះទេ"[44]។ ចេតនារបស់សហព្រះរាជអាជ្ញាក្នុងការពុំបានលាតត្រដាងឲ្យបានពេញលេញនៅក្នុងលិខិតធានាអះអាងអំពីការមិនចោទប្រកាន់នោះ បានបង្កើតជាការមន្ទិលសង្ស័យចំពោះភាពស្មោះត្រង់របស់សហព្រះរាជអាជ្ញា។

១៥ នៅក្នុងកថាខណ្ឌ ១៦ សហព្រះរាជអាជ្ញាអះអាងថា អាជ្ញាយុកាលដែលមានរយៈពេល១០ឆ្នាំសម្រាប់បទឧក្រិដ្ឋក្នុងស្រុក ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានអស់សុពលភាព ហើយសម្រាប់តុលាការកម្ពុជាទាំងអស់ លើកលែងតែ អ.វ.ត.ក ចំពោះបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តនៅមុន ឬនៅ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ សហព្រះរាជអាជ្ញាបញ្ជាក់ទៀតថា ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៩២ របស់អ៊ុនតាក់ (UNTAC) គឺមានរំពឹងទុកសម្រាប់ការអនុវត្ត និងពុំមានបទប្បញ្ញត្តិណាមួយសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិឡើយ។ ទោះបីជាការអះអាងនេះត្រឹមត្រូវក៏ដោយ ក៏គេត្រូវអានការអះអាងទាំងនេះ ដោយពិចារណាទៅលើការអះអាងពីមុនរបស់សហព្រះរាជអាជ្ញាដែលថា "ច្បាប់អន្តរជាតិតម្រូវឲ្យមានការផ្តន្ទាទោសបទល្មើសជាតិដែលឈានដល់កម្រិតបទល្មើសអន្តរជាតិ សូម្បីតែអាជ្ញាយុកាលបានគាំទ្រការរារាំងមិនឲ្យមានការផ្តន្ទាទោសទាំងនោះក៏ដោយ"[45] ហើយថា អ.វ.ត.ក "គួរតែបដិសេធការអនុវត្តអាជ្ញាយុកាលណាមួយចំពោះបទឧក្រិដ្ឋរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពីព្រោះ បទឧក្រិដ្ឋទាំងនេះក៏បង្កើតបានជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភធ្ងន់ធ្ងរទៅលើ

---

ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D427/1/17 កថាខណ្ឌ ១៤៩។ គោលជំហររបស់មេធាវីការពារក្តី ត្រូវបានបដិសេធដោយ អង្គបុរេជំនុំជម្រះ ដែលបានពិចារណាតែទៅលើសមត្ថភាពរបស់ អ.វ.ត.ក ប៉ុណ្ណោះ (ជាជាងតុលាការជាតិផ្សេងៗទៀត) ក្នុងការផ្តន្ទាទោសបទឧក្រិដ្ឋអន្តរជាតិ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២១៣។

[44] ចម្លើយតបរួម របស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D427/1/17 កថាខណ្ឌ ១៤៩។

[45] ដូចយោងខាងលើ ផ្នែក ច.៣.៨។

អនុសញ្ញាទីក្រុងហ្សឺណែវដែរ"[46]។ នៅពេលដែលវាងាយស្រួលសម្រាប់ពួកគាត់ សហព្រះរាជអាជ្ញា មានចេតនាអះអាងដោយពុំមានការអៀនខ្មាសឡើយថា អាជ្ញាយុកាលរារាំងមិនឲ្យមានការផ្ដន្ទាទោស នៅពេលអនាគត ចំពោះបទល្មើសនានា សូម្បីតែបទល្មើសទាំងនោះឈានដល់កម្រិតបទល្មើស អន្តរជាតិក៏ដោយ (ជាគោលជំហរមួយផ្ទុយទៅនឹងការអះអាងពីលើកមុន)។ ដោយឡែកនៅទន្ទឹម ពេលគ្នានេះដែរ មានការប្រកាសជាសាធារណៈ ថាតើជនរងគ្រោះដែលមិនស្ថិតនៅក្នុងអាជ្ញាយុកាល របស់អ.វ.ត.ក គួរទទួលបានយុត្តិធម៌បែបណា នៅក្នុងកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ នាពេលខាងមុខ[47]។ អំពើពុតត្បុតគឺមិនត្រឹមត្រូវឡើយ។

១៦ នៅក្នុងកថាខណ្ឌ ១៧ សហព្រះរាជអាជ្ញាបញ្ជាក់ថា វាជាការសមស្របក្នុងការជម្រាបជូនសាក្សីអំពី "តថភាពផ្លូវច្បាប់៖ ដូចជាច្បាប់កម្ពុជាបច្ចុប្បន្ន មិនមានចែងអំពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងសម័យឆ្នាំ១៩៧៥-១៩៧៩ នៅចំពោះមុខតុលាការក្នុងស្រុកឡើយ"។ ការអះអាង នេះ គឺជាល្បិចកលមួយ។ សាក្សីត្រូវតែទទួលបាននូវព័ត៌មានពេញលេញអំពីផលប៉ះពាល់ដែលអាច កើតមាន នៃការធ្វើសក្ខីកម្មរបស់ពួកគាត់ រួមទាំងការចោទប្រកាន់ផងដែរ ទោះបីជាការចោទ ប្រកាន់នោះមិនទំនងជាអាចមានក៏ដោយ។ នេះគឺជា "តថភាពផ្លូវច្បាប់" ដូចដែលយើងឃើញមាន ការចោទប្រកាន់លើលោក អៀង សារី ដែលកំពុងតែដំណើរការនៅពេលនេះជាភ័ស្តុតាងស្រាប់។ នៅក្នុងឆ្នាំ១៩៩៦ នៅពេលដែលលោក អៀង សារី ទទួលបានព្រះរាជទានលើកលែងទោស និងអនុគ្រោះទោស[48] ពុំមានច្បាប់ដែលកំពុងរង់ចាំការអនុម័តដើម្បីបង្កើត អ.វ.ត.ក ឡើយ។

---

[46] ដូចយោងខាងលើ កថាខណ្ឌ ១២០។

[47] លិខិតផ្ញើជូននិពន្ធនាយក កាសែត CAMBODIA DAILY ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១២ Andrew Cayley QC *ការិយាល័យ សហព្រះរាជអាជ្ញាមិនមែនមិនអើពើចំពោះបទល្មើសរំលោភលើផ្លូវភេទក្នុងរបបខ្មែរក្រហមនោះទេ* "ស្ត្រីជាច្រើន នៅក្នុងប្រទេស នេះកំពុងរស់នៅដោយក្ដីឈឺចាប់យ៉ាងស្ងប់ស្ងៀម ដែលបណ្ដាលមកពីការចាប់រំលោភ និងហិង្សាលើផ្លូវភេទ ដែលបានកើតឡើង អស់រយៈពេលជាងសាមសិបឆ្នាំកន្លងមកហើយ។ ភាពអាម៉ាស់ និងស្លាកស្នាមទុយ៌សនៅព័ទ្ធជុំវិញពួកគេ។ ពួកគេសមតែទទួលបានការអាណិតអាសូរ ហើយពួកគេសមតែទទួលបានយុត្តិធម៌ ប៉ុន្តែ អ.វ.ត.ក មិនអាចបំពេញនូវរាល់ តម្រូវការទាំងអស់របស់ជនរងគ្រោះទាំងនេះទេ"។

[48] ព្រះរាជក្រឹត្យ នស/រកត០៩៩៦/៧២ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦។

១៧ នៅក្នុងកថាខណ្ឌ ១៨ សហព្រះរាជអាជ្ញាអះអាងថា អង្គភាពគាំពារការពារក្តី (“DSS”) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៅក្នុងខែ សីហា ឆ្នាំ ២០១១ សម្រាប់មេធាវីដែលត្រូវផ្តល់ប្រឹក្សាដល់សាក្សី ហើយពុំបានបង្ហាញពីការមិនឯកភាពទៅនឹងការយល់ឃើញរបស់សហព្រះរាជអាជ្ញាអំពីច្បាប់កម្ពុជា ដូចដែលបានបញ្ជាក់នៅក្នុងសំណើឡើយ។ ការអះអាងនេះគឺមិនអាចឲ្យជឿជាក់បាន និងគ្មានសារៈសំខាន់ឡើយ។ ទោះបីជា DSS អាចបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលមេធាវីដើម្បីតំណាងឲ្យសាក្សីដែលត្រូវបានរំពឹងថា នឹងធ្វើសក្ខីកម្មនៅក្នុងសំណុំរឿង ០០២ ក៏ដោយ ក៏ប្រការនេះមិនពាក់ព័ន្ធឡើយទៅនឹងការផ្តល់ព័ត៌មានមិនពិតទៅឲ្យសាក្សី និង/ឬការមិនផ្តល់ព័ត៌មានមួយចំនួនទៅឲ្យសាក្សី។ សហព្រះរាជអាជ្ញាបញ្ជាក់ទៀតថា សហព្រះរាជអាជ្ញា “មិនជំទាស់ទៅនឹងការផ្តល់ច្បាប់ចម្លងនៃសំណើនេះមួយច្បាប់ ឬសេចក្តីសង្ខេប ជូនទីប្រឹក្សាច្បាប់ដែលកំពុងជួយសាក្សី ហើយដែលសាក្សីនេះបានទទួលលិខិតធានាមិនធ្វើការចោទប្រកាន់រួចហើយ”។ ការអះអាងនេះគឺពុំមានការទទួលខុសត្រូវឡើយ។ វាគ្រាន់តែជាការផ្តល់នូវព័ត៌មានមិនពិត និង/ឬជាការមិនផ្តល់ព័ត៌មានមួយចំនួនទៅឲ្យមេធាវីតំណាងឲ្យសាក្សីតែប៉ុណ្ណោះ។

១៨ នៅក្នុងកថាខណ្ឌ ១៩ សហព្រះរាជអាជ្ញាអះអាងថា “សហព្រះរាជអាជ្ញាមានឆន្ទៈពិចារណាក្នុងការចេញលិខិតធានាមិនធ្វើការចោទប្រកាន់ដល់សាក្សីណាក៏ដោយ រួមទាំងសាក្សីដែលអង្គជំនុំជម្រះសម្រេចកោះហៅតាមសំណើរបស់មេធាវីការពារក្តីផងដែរ”។ ការអះអាងនេះពុំមានលក្ខណៈសមហេតុផលប្រកបដោយភាពថ្លៃថ្នូរឡើយ ពីព្រោះ ការអះអាងនេះមិនពាក់ព័ន្ធទៅនឹងភាពពិតប្រាកដ និងភាពពេញលេញរបស់លិខិតធានាមិនធ្វើការចោទប្រកាន់ និងមិនពាក់ព័ន្ធទៅនឹងភាពសមស្រប ក្នុងការផ្តល់ទៅឲ្យសាក្សីនោះទេ។

១៩ នៅក្នុងកថាខណ្ឌ ២០ សហព្រះរាជអាជ្ញាអះអាងថា លទ្ធភាពនៃការចោទប្រកាន់នៅក្នុងប្រទេសដទៃទៀត នៅក្រោមទ្រឹស្តីនៃយុត្តាធិការជាសកល គឺមិនទំនងជាអាចមាន ដែលធ្វើឲ្យការជូនដំណឹងដល់សាក្សីអំពីលទ្ធភាពនេះ គឺជាការមិនចាំបាច់ឡើយ។ ការអះអាងនេះគឺនាំឲ្យមានការភ័ន្តច្រឡំ។ ដោយមិនគិតអំពីភាពត្រឹមត្រូវនៃការអះអាងនេះ ដែលមេធាវីការពារក្តីមិនទទួលយកនោះ ការអះអាងនេះ ពិតណាស់មិនអាចស៊ីសង្វាក់គ្នាជាមួយនឹងការបញ្ជាក់ដដែលៗរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ William Smith ដល់អង្គជំនុំជម្រះសាលាដំបូង ថា *នៅតែមានលទ្ធភាព*

*នៃការចោទប្រកាន់ ទោះបីជាលទ្ធភាពនោះមិនទំនងជាអាចមានយ៉ាងណាក៏ដោយ*[49] សាក្សីមានសិទ្ធិបដិសេធមិនឆ្លើយទៅនឹងសំណួរដែលអាចដាក់បន្ទុកលើខ្លួនឯងនោះទេ។ ឧទាហរណ៍មួយអំពីទីកន្លែងដែលសាក្សីអាចត្រូវបានចោទប្រកាន់ គឺនៅក្នុងប្រទេសវៀតណាម ទោះបីជាមិនចាំបាច់ស្ថិតនៅក្រោមទ្រឹស្តីនៃយុត្តាធិការជាសកលក៏ដោយ។ របាយការណ៍សារព័ត៌មានថ្មីៗនេះបានបញ្ជាក់ថា ប្រជាជនកម្ពុជាអាចបានប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងប្រទេសវៀតណាម ក្នុងអំឡុងកាលពីចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩[50]។ លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ មិនមានបញ្ចូលនូវព័ត៌មានឲ្យសាក្សីបានដឹងឡើយថា ការចោទប្រកាន់នៅក្នុងប្រទេសវៀតណាម នៅតែអាចធ្វើទៅបានដដែលចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅលើទឹកដីវៀតណាម។

២០ នៅក្នុងកថាខណ្ឌ ២១ សហព្រះរាជអាជ្ញាអះអាងថា "ការផ្តល់ជូននូវការធានា និងព័ត៌មានទាំងឡាយ ដែលមាននៅក្នុងលិខិតធានាមិនធ្វើការចោទប្រកាន់ គឺស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌"។ ការអះអាងនេះនាំឲ្យខូចដល់ដំណើរការយុត្តិធម៌៖[51] វាមិនអាចស្ថិតនៅក្នុងផលប្រយោជន៍យុត្តិធម៌ឡើយសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការផ្តល់ព័ត៌មានមិនពិតទៅឲ្យសាក្សី ដើម្បីបញ្ឆោះបញ្ចូលពួកគេឲ្យលះបង់ចោលនូវសិទ្ធិមួយចំនួន ស្របតាមរដ្ឋធម្មនុញ្ញនោះ។ សហព្រះរាជអាជ្ញា

---

[49] ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/58.1 ទំព័រ ៧៤ បន្ទាត់ ១៩-២៥ (ភាសាអង់គ្លេស)។

[50] "ចៅក្រមបានបើកការស៊ើបអង្កេតដល់ទីកន្លែងទៅក្នុងវិវាទរវាងប្រទេសកម្ពុជា និងវៀតណាមក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និងបានអះអាងថា បានរកឃើញ"អង្គហេតុថ្មីៗ" អំពីសង្គ្រាមនោះ។ "អង្គហេតុថ្មីៗ" ទាំងនេះរួមមាន "ការវាយប្រហារដោយព្រាងទុកជាមុនទៅលើភូមិវៀតណាមដែលមានតែជនស៊ីវិលគ្មានការការពារខ្លួន" និងការសន្និដ្ឋានដែលថា ការវាយប្រហារស្រដៀងគ្នាដទៃទៀតបានកើតឡើង ស្របជាមួយនឹងភស្តុតាងដទៃទៀតនៃការលុកលុយម្តងហើយម្តងទៀតទៅក្នុងទឹកដីវៀតណាម"។ *មន្ត្រីកម្ពុជាដែលត្រូវបានកំណត់ឈ្មោះនៅក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រហម,* កាសែត WA TODAY ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១២ *អាចរកបាននៅលើគេហទំព័រ៖* http://www.watoday.com.au/world/cambodian-officials-named-over-khmer-rouge-genocide-20120602-1zosv.html

[51] វចនានុក្រម Oxford English Dictionary បានកំណត់និយមន័យពាក្យថា "ធ្វើឲ្យខូច កិ." ("pervert, v.") ជា "ការចូលជ្រៀតជ្រែក ឬធ្វើឲ្យខុស (នូវលំដាប់លំដោយ ឬដំណើរការត្រឹមត្រូវមួយ) បង្អាក់ ឬបង្កជាឧបសគ្គ (ផ្នែកយុត្តិធម៌ ។ល។)។ ជាសំខាន់ច្បាប់ នៅក្នុងការប្រើប្រាស់ក្រោយៗមកទៀត ជាពិសេស នៅក្នុងការធ្វើឲ្យខូចដំណើរការយុត្តិធម៌ (បទល្មើសដែលអាចចោទប្រកាន់បានក្រោមច្បាប់ប្រព័ន្ធខំមិនឡូនៅ ចក្រភពអង់គ្លេស)"។ OXFORD ENGLISH DICTIONARY (លើប្រព័ន្ធអ៊ីនធឺណិត ខែ មិថុនា ឆ្នាំ ២០១២) *អាចរកបាននៅលើគេហទំព័រ៖* http://www.oed.com/view/Entry/141685?redirectedFrom=pervert+the+course+of+justice#eid31012991។

ស្វះស្វែងស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងជួយ និងជំរុញផ្តល់ព័ត៌មានមិនពិតទៅឲ្យសាក្សី ដោយអះអាងថា "ស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌"[52]។ សហព្រះរាជអាជ្ញាហាក់ដូចជាអះអាងថា ខ្លួនត្រូវប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីសម្រេចបាននូវគោលដៅ ដែលហាក់ដូចជា ដំណើរការចាស់គំរឹលហួសសម័យទៅហើយ ហើយដែលតាមពិតទៅវាផ្ទុយទៅនឹងផលប្រយោជន៍នៃយុត្តិធម៌ទៀតផង។

២១ នៅក្នុងកថាខណ្ឌ ២២ សហព្រះរាជអាជ្ញាអះអាងថា "អាចជាការសមស្របដើម្បីបន្ថែមលិខិតទទួលស្គាល់នូវការធានាអះអាងអំពីការមិនចោទប្រកាន់ ទៅលើការរំឭកមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង"។ ការអះអាងនេះគឺមិនត្រឹមត្រូវឡើយ។ ការទទួលស្គាល់គឺគ្រាន់តែធ្វើឲ្យត្រឹមត្រូវតាមច្បាប់នូវការដណ្តើមយកអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ពីសំណាក់សហព្រះរាជអាជ្ញាប៉ុណ្ណោះ។

២២ នៅក្នុងកថាខណ្ឌ ២៣ និង ២៤ សហព្រះរាជអាជ្ញា មិនមានបន្ថែមអ្វីឡើយ គ្រាន់តែបញ្ជាក់ឡើងវិញ នូវសំណើរបស់ខ្លួនស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងយល់ស្របតាមសំណើប៉ុណ្ណោះ និងការស្នើឡើងរបស់ខ្លួនថា ប្រសិនបើអង្គជំនុំជម្រះសម្រេចទទួលយកសំណើនេះ ការទទួលស្គាល់លិខិតធានាមិនធ្វើការចោទប្រកាន់ ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌ ២២ ត្រូវផ្តល់ជូនទៅឲ្យ

---

[52] ប្រសិនបើចៅក្រមអង្គជំនុំជម្រះសាលាដំបូងជួយនិងជំរុញសហព្រះរាជអាជ្ញាមែននោះ ពួកគេនឹងរំលោភលើមាត្រា៣(៣) នៃកិច្ចព្រមព្រៀង ("ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់") មាត្រា ១០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ("[ចៅក្រម]ត្រូវមានចរិតលក្ខណៈ និងស្មារតីខ្ពស់")។ និងក្រមសីលធម៌សម្រាប់ចៅក្រម។ មាត្រា៥(១) នៃក្រមសីលធម៌សម្រាប់ចៅក្រមនៅ អ.វ.ត.ក ចែងថា៖ "ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្តីសង្វាតព្យាយាម និងប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនដើម្បីបំពេញភារកិច្ចទាំងនោះ"។ មាត្រា ១៨ នៃក្រមសីលធម៌ចៅក្រមកម្ពុជាចែងថា៖ "ចៅក្រមគឺជាបុគ្គលដែលទៀងត្រង់"។ កថាខណ្ឌ ៦៦ នៃ សេចក្តីណែនាំសម្រាប់ក្រមសីលធម៌ចៅក្រមនូវ៉ែលសេឡង់ចែងថា៖ "ចៅក្រមត្រូវបំពេញមុខងាររបស់ខ្លួនប្រកបដោយសេចក្តីសង្វាតព្យាយាម និងយ៉ាងពេញលេញ។ កាតព្វកិច្ចទាំងនេះមិនត្រឹមតែសំដៅដល់ភាពទៀងត្រង់វិជ្ជាជីវៈក្នុងការវិនិច្ឆ័យ និងការបំពេញការងារឲ្យបានត្រឹមត្រូវប៉ុណ្ណោះទេ តែគឺឆន្ទៈក្នុងការបែងចែកការងារឲ្យបានត្រឹមត្រូវនៅតុលាការផងដែរ"។ គោលការណ៍ គ.៦ នៃ Recueil des obligations déontologiques des magistrats ចែងថា៖ "សុចរិតភាពរបស់ចៅក្រមសំដៅដល់លក្ខខណ្ឌតម្រូវជាទូទៅនៃភាពស្មោះត្រង់"។ (ការបកប្រែក្រៅផ្លូវការពី៖ "La probité du magistrat s'entend de l'exigence générale d'honnêteté.")។ Value 2, Application 2.2 នៃគោលការណ៍ Bangalore ស្តីពីក្រមសីលធម៌ចៅក្រមឆ្នាំ ២០០២ ចែងថា៖ "ចៅក្រមត្រូវធានាថាការប្រព្រឹត្តិរបស់ខ្លួន ទាំងនៅក្នុង ក៏ដូចជានៅខាងក្រៅតុលាការ រក្សា និងបង្កើនជំនឿជឿជាក់របស់សាធារណជន វិជ្ជាជីវៈផ្នែកច្បាប់ និងភាគីក្នុងរឿងក្តីទៅលើភាពមិនលម្អៀងរបស់ចៅក្រម និងស្ថាប័នតុលាការ"។

សាក្សី។ ដូចដែលបានលើកទឡ្ហីករណ៍នៅខាងលើរួចហើយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ស្របតាមសំណើរបស់សហព្រះរាជអាជ្ញា និងទទួលយកការស្នើឡើងរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះនឹងជួយ និងជំរុញដល់សហព្រះរាជអាជ្ញា ក្នុងការផ្តល់នូវព័ត៌មានមិនពិតទៅឲ្យសាក្សី និង/ឬផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ទៅឲ្យសាក្សី ហើយប្រសិនបើធ្វើដូច្នេះ វានឹងធ្វើឲ្យមានការបោះបង់ចោលការទទួលខុសត្រូវផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូង ដោយអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដណ្តើមយកអំណាចរបស់ខ្លួននោះ មានលក្ខណៈស្របច្បាប់ផងដែរ។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូង**បដិសេធ**សំណើនេះ។

សូមលោក-លោកស្រីចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកចម្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**